# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៥ . សសរ

## សេចក្ដីសម្រេច

ស្ដីពី

ការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីចរចាជាមួយភាគីចិនអំពីការទិញនាវា ប្រយុទ្ធប្រឆាំងនឹងការរត់ពន្ធតាមដងសមុទ្រ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងលើស្មារតីនៃការពិភាក្សារវាងថ្នាក់ដឹកនាំកំពូលនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន ក្នុងឱកាសសម្ដេចនាយករដ្ឋមន្ត្រីអញ្ជើញទៅទស្សនកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិន
- យោងស្មារតីនៃកិច្ចពិភាក្សារវាងគណៈប្រតិភូរាជរដ្ឋាភិបាលកម្ពុជា និង Exim Bank

## ស ម្រេ ច

**ប្រការ ១ :** ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីចរចាជាមួយភាគីចិនអំពីការទិញនាវាប្រយុទ្ធប្រឆាំងនឹងការរត់ពន្ធតាមដងសមុទ្រ ដូចមានសមាសភាពខាងក្រោម :

១- ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាន

២- ឯកឧត្តមឧត្តមសេនីយ៍ឯក **អ៊ុង សំខាន់** មេបញ្ជាការកងទ័ពជើងទឹក អនុប្រធាន

៣- ឯកឧត្តម **ជា ចាន់ដេត** នាយកខុទ្ទកាល័យ និងទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី សុខ អាន សមាជិក

៤- លោក **ង៉ោ យុទ្ធថា** ប្រធានការិយាល័យសហប្រតិបត្តិការទ្វេភាគី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

**ប្រការ ២** : ក្រុមការងារនេះមានភារកិច្ចដូចតទៅ :

- ចរចាជាមួយភាគីចិន
- ពិនិត្យការសិក្សាបឋម
- ពិនិត្យកិច្ចព្រមព្រៀងទិញលក់
- ពិនិត្យកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន
- តាមដានការអនុវត្តកិច្ចព្រមព្រៀងទិញ-លក់

**ប្រការ ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ និងសាមីខ្លួន ដូចមាន ក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល** :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ ✓